អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## សវនាការជំនុំជម្រះក្តីឌុចមានអ្នកទស្សនាជាង ២០០០០ នាក់

នាថ្ងៃពុធ ទី២៦ ខែសីហា ឆ្នាំ២០០៩នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រេចនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតដោយបានទទួលសាធារណជនចំនួនជាង **២០០០០** (ពីរម៉ឺន) **នាក់** ចូលមកទស្សនាដំណើរការជំនុំជម្រះក្តីលេខ០០១ ប្រឆាំងនឹងជនជាប់ចោទកាំង ហ្កេកអ៊ាវ ហៅឌុច។

ដោយគិតមកត្រឹមថ្ងៃពុធ ទី២៦ ខែសីហា ឆ្នាំ២០០៩ នេះ មានសាធារណជនចំនួន ២០២៥០ នាក់ (ពីរម៉ឺនពីររយហាសិប) បានមកចូលរួមទស្សនាសវនាការ ឌុច ចាប់តាំងពីពេលចាប់ផ្តើមសវនាការនាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។ សម្រាប់ចំនួនតួលេខនេះគឺគិតជាមធ្យមមានអ្នកទស្សនា ៣១១ នាក់ក្នុងមួយថ្ងៃ។ ចំនួនសាធារណជនទាំងអស់នេះ គឺមកពី ១១ ខេត្តនិងរាជធានី ដែលរួមមាន ខេត្តកណ្តាល កំពង់ចាម កំពង់ស្ពឺ ពោធិសាត់ កំពង់ធំ កំពង់ឆ្នាំង ក្រចេះ សៀមរាប តាកែវ កំពត និងរាជធានីភ្នំពេញ។ ដោយឡែកមានភ្ញៀវបរទេសមកពី២២ ប្រទេសផ្សេងៗគ្នាបានចូលរួមទស្សនាដំណើរការនីតិវិធីតុលាការ។

ក្នុងរយៈកាលប៉ុន្មានខែកន្លងមកនេះ ផ្នែកកិច្ចការសាធារណៈបានខិតខំពង្រឹងលទ្ធភាពការងាររបស់ខ្លួនលើផ្នែកកិច្ចការផ្សព្វផ្សាយ និងការចូលរួមរបស់សាធារណៈជននៅតុលាការនេះ។ ដោយសារការកំណត់គោលដៅផ្សព្វផ្សាយដ៏មានប្រសិទ្ធិភាពតាមរយៈវិទ្យុ ទូរទស្សន៍ និងបណ្តាញសារព័ត៌មានផ្សេងៗទៀត តុលាការអាចមានលទ្ធភាពយ៉ាងទូលំទូលាយក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនានាអំពីមធ្យោបាយក្នុងការចូលរួមសវនាការ។

អ.វ.ត.ក បាន និងកំពុងផ្តល់សេវាកម្មដឹកជញ្ជូនតាមរថយន្តក្រុងពីខេត្តក្រុងនានាមកកាន់តុលាការ សម្រាប់ក្រុមសាធារណជនចាប់ពី៣០នាក់ឡើងដែលមានបំណងចង់ចូលរួមក្នុងដំណើរការសវនាការរបស់ឌុចនេះ។

ក្នុងរយៈពេលប្រាំខែនៃសវនាការរបស់ឌុច មានប្រជាពលរដ្ឋជាច្រើនមានចំណាប់អារម្មណ៍ទស្សនាដំណើរការជំនុំជម្រះក្តី ឌុច ដោយផ្ទាល់ និងដោយប្រយោល។ សម្រាប់រយៈពេលរហូតដល់ថ្ងៃទី ១៧ ខែកញ្ញា ខាងមុខទៀតនេះ កន្លែងអង្គុយនៅក្នុងសាលសវនាការត្រូវបានកក់ពេញរួចជាស្រេចហើយដោយសាធារណជនថ្មីៗទៀត។

| **កាលបរិច្ឆេទនៃសវនាការ (គិតជាសប្តាហ៍)** | **ចំនួនអ្នកចូលទស្សនា (ប្រចាំសប្តាហ៍)** |
|---|---:|
| 30/03/09 - 01/04/09 | 1,176 |
| 06/04/09 - 09/04/09 | 623 |
| 20/04/09 - 23/04/09 | 642 |
| 27/04/09 - 30/04/09 | 742 |
| 18/05/09 - 21/05/09 | 575 |
| 25/05/09 - 28/05/09 | 560 |
| 08/06/09 - 10/06/09 | 415 |
| 15/06/09 - 170/6/09 | 621 |
| 22/06/09 - 25/06/09 | 860 |
| 29/06/09 - 02/07/09 | 1,899 |
| 06/07/09 - 09/07/09 | 1,553 |
| 13/07/09 - 16/07/09 | 1,504 |
| 20/07/09 - 22/07/09 | 1,301 |
| 27/07/09 - 28/07/09 | 1,094 |
| 03/08/09 - 06/08/09 | 1,687 |
| 10/08/09 - 12/08/09 | 1,463 |
| 17/08/09 - 20/08/09 | 2,176 |
| 24/08/09 - 26/08/09 | 1,359 |
| **ចំនួនសរុបរួមគិតត្រឹមថ្ងៃពុធ ទី២៦ ខែសីហាឆ្នាំ២០០៩** | **20,250** |

## សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង

លោករាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោកឌីម សុវណ្ណារុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោកឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org

លោកស្រី យូកូ មេដា
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ: +855 (0) 12 488 319
ទូរស័ព្ទលេខ: +855 (0) 23 219 814 លេខបន្ត 6139
សារអេឡិចត្រូនិច: maeday@un.org